**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**

**<u>នាយកដ្ឋានព័ត៌មាន</u>**

# សេចក្តីប្រកាសព័ត៌មាន
# លទ្ធផលនៃការអញ្ជើញចូលរួមកិច្ចប្រជុំកំពូលរំលឹកខួបអនុស្សាវរីយ៍អាស៊ាន-សាធារណរដ្ឋកូរ៉េ និង កិច្ចប្រជុំកំពូលមេគង្គ-សាធារណរដ្ឋកូរ៉េលើកទី១
# របស់ឯកឧត្តម ប្រាក់ សុខុន ឧបនាយករដ្ឋមន្ត្រី
# រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

ទីក្រុងប៊ូសាន ថ្ងៃទី ២៤ ដល់ថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ២០១៩

* * * * *

ឯកឧត្តម ប្រាក់ សុខុន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ តំណាងដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញចូលរួមកិច្ចប្រជុំកំពូលរំលឹកខួបអនុស្សាវរីយ៍អាស៊ាន-សាធារណរដ្ឋកូរ៉េ និងកិច្ចប្រជុំកំពូលមេគង្គ-សាធារណរដ្ឋកូរ៉េលើកទី១ នៅទីក្រុងប៊ូសាន ពីថ្ងៃទី២៤ ដល់ថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ២០១៩។

<u>កិច្ចប្រជុំកំពូលរំលឹកខួបអនុស្សាវរីយ៍អាស៊ាន-សាធារណរដ្ឋកូរ៉េ</u>

មូលបទនៃកិច្ចប្រជុំកំពូលរំលឹកខួបអនុស្សាវរីយ៍អាស៊ាន-សាធារណរដ្ឋកូរ៉េ គឺ «ភាពជាដៃគូសម្រាប់សន្តិភាព វិបុលភាពសម្រាប់ប្រជាជន»។ នៅក្នុងសម័យប្រជុំអំពី **«អាស៊ាន-សាធារណរដ្ឋកូរ៉េ ៣០ និង ៣០»** ថ្នាក់ដឹកនាំបានពិនិត្យមើលឡើងវិញនូវសមិទ្ធិផលនៃកិច្ចសហប្រតិបត្តិការអាស៊ាន-សាធារណរដ្ឋកូរ៉េ ក្នុងរយៈពេល៣០ឆ្នាំកន្លងមកនេះ និងបានកំណត់កិច្ចសហប្រតិបត្តិការពេលអនាគតសម្រាប់រយៈពេលបីទសវត្សរ៍ទៅមុខ។ ថ្នាក់ដឹកនាំបានផ្លាស់ប្តូរយោបល់គ្នាទៅវិញទៅមកសំដៅលើកកម្ពស់ការតភ្ជាប់ឆ្ពោះទៅកាន់វិបុលភាព និងបន្តចូលរួមកិច្ចប្រជុំលក្ខណៈចង្អៀត ដើម្បីពិភាក្សាអំពីបញ្ហាសន្តិភាពនៅឧបទ្វីបកូរ៉េ។

ថ្នាក់ដឹកនាំអាស៊ានបានអបអរសាទរចំពោះគោលនយោបាយទិសខាងត្បូងថ្មីរបស់ ឯកឧត្តម **មូន ចែអ៊ីន** ប្រធានាធិបតីនៃសាធារណរដ្ឋកូរ៉េ ដែលកសាងឡើងដោយឈរលើសរសរស្តម្ភបី (3P) «ប្រជាជន វិបុលភាព និងសន្តិភាព» ដែលជាការពង្រឹងការផ្តោតគោលនយោបាយការបរទេសរបស់សាធារណរដ្ឋកូរ៉េទៅកាន់អាស៊ាន។ កិច្ចប្រជុំបានវាយតម្លៃខ្ពស់នូវតួនាទីដ៏សកម្មរបស់សាធារណរដ្ឋកូរ៉េ នៅក្នុងការគាំទ្រមជ្ឈភាពអាស៊ាន តាមរយៈទំនាក់ទំនងយ៉ាងសកម្មរបស់ខ្លួននៅក្នុងយន្តការនានាដែលដឹកនាំដោយអាស៊ាន ដែលបានរួមចំណែកយ៉ាងសំខាន់ដល់សន្តិភាព សន្តិសុខ និងវិបុលភាពនៅក្នុងតំបន់។ ថ្នាក់ដឹកនាំបានជំរុញឲ្យមានកិច្ចសហប្រតិបត្តិការ



អាសយដ្ឋាន: លេខ ៣ វិថី **សម្តេច ហ៊ុន សែន**
សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 214 441, 216 122
ទូរសារ : (855) 23 216 144, 216 141
អ៊ីម៉ែល : mfaic@mfa.gov.kh

កាន់តែរឹងមាំឡើងលើបញ្ហាឧក្រិដ្ឋកម្មឆ្លងដែន ការប្រឆាំងអំពើ ភេរវនិយម គ្រឿងញៀន សន្តិសុខអ៊ិនធឺណែត សន្តិសុខអាហារនិងថាមពល ការគ្រប់គ្រងគ្រោះមហន្តរាយដែលពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ និង បញ្ហាដទៃផ្សេងទៀត។

ថ្នាក់ដឹកនាំបានកត់សម្គាល់នូវទំនាក់ទំនងសេដ្ឋកិច្ចដ៏រឹងមាំរវាងអាស៊ាន និងសាធារណរដ្ឋកូរ៉េ និង បានបង្ហាញការប្តេជ្ញាចិត្តយ៉ាងមុតមាំចំពោះប្រព័ន្ធពាណិជ្ជកម្មពហុភាគីនិយម ដែលឈរលើគោលការណ៍វិធាន ច្បាប់ និងចំពោះការប្រើប្រាស់ប្រកបដោយប្រសិទ្ធភាពនូវកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-សាធារណរដ្ឋ កូរ៉េ និងបានជំរុញការបញ្ចប់ឲ្យបានឆាប់ភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់ (RCEP) នៅក្នុងចំណោម ប្រទេសដែលចូលរួមទាំង១៥ នៅដើមឆ្នាំក្រោយ។ ថ្នាក់ដឹកនាំអាស៊ាន បានថ្លែងអំណរគុណចំពោះការគាំទ្រ របស់សាធារណរដ្ឋកូរ៉េ នៅក្នុងដំណើរការសមាហរណកម្មតំបន់ និងការកសាងសហគមន៍អាស៊ាន តាមរយៈ មូលនិធិសហប្រតិបត្តិការអាស៊ាន-សាធារណរដ្ឋកូរ៉េ និងគំនិតផ្តួចផ្តើមសមាហរណកម្មអាស៊ាន។ ថ្នាក់ដឹកនាំ បានទទួលស្គាល់នូវការឈានមុខរបស់សាធារណរដ្ឋកូរ៉េក្នុងវិស័យបច្ចេកវិទ្យា និងនវានុវត្តន៍ និងបានលើកទឹក ចិត្តឲ្យសាធារណរដ្ឋកូរ៉េគាំទ្រដល់ការអភិវឌ្ឍធនធានមនុស្ស ការអប់រំ និងការកសាងសមត្ថភាព ដើម្បីជួយ ដល់តំបន់ក្នុងការកាត់បន្ថយគម្លាតឌីជីថល។

ឯកឧត្តម **ប្រាក់ សុខុន** បានបញ្ជាក់អំពីភាពចំបាច់ក្នុងការប្រែក្លាយ «សេចក្តីថ្លែងការណ៍រួម ស្តីពីអាស៊ាន-សាធារណរដ្ឋកូរ៉េ សម្រាប់សន្តិភាព វិបុលភាព និងភាពជាដៃគូ» ឲ្យទៅជាសកម្មភាពពិតប្រាកដ ដែលនឹងត្រូវបានឆ្លុះបញ្ចាំងនៅក្នុង «ផែនការសកម្មភាពថ្មី សម្រាប់រយៈពេល៥ឆ្នាំ (២០២១-២០២៥)»។ **ឯកឧត្តម** បានជំរុញសាធារណរដ្ឋកូរ៉េឲ្យបន្តពង្រឹងកិច្ចសហប្រតិបត្តិការជាមួយអាស៊ាន តាមរយៈការចែករំលែក ចំណេះដឹង ការអនុវត្តល្អៗ និងជំនួយបច្ចេកទេស។ **ឯកឧត្តម** បានសម្តែងក្តីសង្ឃឹមថា កម្ពុជានឹងទទួលបានផល ប្រយោជន៍បន្ថែមទៀត ពីជំនួយបច្ចេកទេសរបស់សាធារណរដ្ឋកូរ៉េ សម្រាប់ការបណ្តុះបណ្តាលជំនាញ និងការ អភិវឌ្ឍធនធានមនុស្ស នៅក្នុងវិស័យព័ត៌មានវិទ្យានិងបច្ចេកវិទ្យាទូរគមនាគមន៍ (ICT) និងឌីជីថលនវានុវត្តន៍ ដើម្បីកម្ពុជាអាចទទួលបានផលប្រយោជន៍ពីការវិវត្តបដិវត្តន៍ឧស្សាហកម្មទី៤ (4IR) និងបានទទួលស្គាល់អំពី តួនាទីដ៏សំខាន់របស់មជ្ឈមណ្ឌលអាស៊ាន-សាធារណរដ្ឋកូរ៉េ និងមជ្ឈមណ្ឌលវប្បធម៌អាស៊ាន ក្នុងការលើក កម្ពស់ទេសចរណ៍ វប្បធម៌ ពាណិជ្ជកម្ម និងវិនិយោគ នៅក្នុងអាស៊ាន និងនៅសាធារណរដ្ឋកូរ៉េ និងបានគាំទ្រ យ៉ាងពេញទំហឹងចំពោះការដាក់ឈ្មោះ «វិថីអាស៊ាន» លើផ្លូវប្រវែង២គីឡូម៉ែត្រ ដែលរៀបចំដោយសាលាក្រុង ប៊ូសាន ក្នុងស្មារតីលើកកម្ពស់ការយល់ដឹងអំពីវប្បធម៌ រវាងអាស៊ាន និងសាធារណរដ្ឋកូរ៉េ។ **ឯកឧត្តម** ក៏បាន បានជំរុញការបញ្ចប់ឲ្យបានឆាប់ភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់ (RCEP) ដោយប្រទេសចូលរួម ទាំង១៥ នៅដើមឆ្នាំក្រោយ និងបានថ្លែងអំណរគុណចំពោះការរួមចំណែករបស់សាធារណរដ្ឋកូរ៉េ នៅក្នុងការ អនុវត្តផែនការការងារនៃគំនិតផ្តួចផ្តើមសមាហរណកម្មអាស៊ាន (IAI) ដែលជាធាតុដ៏សំខាន់សម្រាប់បង្រួម គម្លាតអភិវឌ្ឍន៍។ សម្រាប់សម័យប្រជុំ «**ការលើកកម្ពស់ការតភ្ជាប់**» **ឯកឧត្តម** បានជំរុញឲ្យសាធារណរដ្ឋកូរ៉េ លើកទឹកចិត្តក្រុមហ៊ុនរបស់ខ្លួន ឲ្យចូលរួមនៅក្នុងគម្រោងការតភ្ជាប់នានា នៅក្នុងបណ្តាប្រទេសជាសមាជិក អាស៊ាន ជាពិសេសនៅក្នុងវិស័យបណ្តាញទីក្រុងឆ្លាត ហេដ្ឋារចនាសម្ព័ន្ធរឹងនិងទន់ និងការបណ្តុះបណ្តាល ជំនាញ ដើម្បីលើកកម្ពស់កំណើនសេដ្ឋកិច្ច និងសុខមាលភាពរបស់ប្រជាជន។

ចំពោះបញ្ហានៅឧបទ្វីបកូរ៉េ **ឯកឧត្តម ប្រាក់ សុខុន** បានស្វាគមន៍ចំពោះការវិវឌ្ឍវិជ្ជមាន ដែលជា លទ្ធផលនៃកិច្ចប្រជុំកំពូលអន្តរកូរ៉េ និងជំនួបកំពូលអាមេរិក-សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េ និង

បានបញ្ជាក់ពីការគាំទ្ររបស់កម្ពុជាចំពោះគោលការណ៍ចំនួន៣ ដែលបានដាក់ចេញដោយ ឯកឧត្តមប្រធានាធិបតី **មូន ចែអ៊ីន** គឺ «គ្មានការអត់អោនចំពោះសង្គ្រាម ការធានាសន្តិសុខទៅវិញទៅមក និងសហវិបុលភាព» និងការប្តេជ្ញាចិត្តរបស់ឯកឧត្តមប្រធានាធិបតី ឆ្ពោះទៅរកដំណោះស្រាយដើម្បីរំសាយអាវុធនុយក្លេអ៊ែរទាំងស្រុង នៅក្នុងឧបទ្វីបកូរ៉េ។

នៅចុងបញ្ចប់នៃកិច្ចប្រជុំកំពូលរំលឹកខួបអនុស្សាវរីយ៍ ថ្នាក់ដឹកនាំបានអនុម័តសេចក្តីប្រកាសទស្សនវិស័យរួមអាស៊ាន-សាធារណរដ្ឋកូរ៉េ សម្រាប់សន្តិភាព វិបុលភាព និងភាពជាដៃគូ និងបានចេញសេចក្តីប្រកាសរបស់សហប្រធាននៃកិច្ចប្រជុំកំពូលរំលឹកខួបអនុស្សាវរីយ៍អាស៊ាន-សាធារណរដ្ឋកូរ៉េ។

<u>កិច្ចប្រជុំកំពូលមេគង្គ-សាធារណរដ្ឋកូរ៉េលើកទី១</u>

នៅក្នុងកិច្ចប្រជុំកំពូលមេគង្គ-សាធារណរដ្ឋកូរ៉េលើកទី១ ដែលបានប្រព្រឹត្តទៅនៅថ្ងៃទី ២៧ ខែវិច្ឆិកា ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់សុខុន បានថ្លែងអំណរគុណចំពោះ ឯកឧត្តមប្រធានាធិបតី **មូន ចែអ៊ីន** និងថ្នាក់ដឹកនាំប្រទេសមេគង្គទាំងអស់ ដែលបានគាំទ្រគំនិតផ្តួចផ្តើមរបស់**សម្តេចតេជោហ៊ុនសែន** ក្នុងការលើកកំពស់រចនាសម្ព័ន្ធការងារនៃក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការមេគង្គ-សាធារណរដ្ឋកូរ៉េ ពីកម្រិតប្រជុំថ្នាក់រដ្ឋមន្ត្រីការបរទេស ឈានដល់កម្រិតកិច្ចប្រជុំកំពូល។ **ឯកឧត្តម** បានកត់សម្គាល់នូវវឌ្ឍនភាពយ៉ាងឆាប់រហ័ស និងសមិទ្ធិផលជាក់ស្តែង នៅក្នុងក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការមេគង្គ-សាធារណរដ្ឋកូរ៉េ ដែលបានរួមចំណែកដល់ការផ្លាស់ប្តូរសេដ្ឋកិច្ច-សង្គមនៃបណ្តាប្រទេសមេគង្គ ក្នុងការអភិវឌ្ឍធនធានមនុស្ស និងឱកាសការងារ។ ចាប់តាំងពីឆ្នាំ២០០៧មក ប្រជាជនកម្ពុជាជាង ៦១០០០នាក់ បានមានឱកាសធ្វើការនៅក្នុងសាធារណរដ្ឋកូរ៉េក្រោមប្រព័ន្ធការអនុញ្ញាតការងារ។ **ឯកឧត្តម** បានគូសបញ្ជាក់អំពីការចូលរួមចំណែករបស់សាធារណរដ្ឋកូរ៉េ ក្នុងការបង្កើនជំនាញរបស់ពួកគេ និងដែលអាចឲ្យពួកគេអាចធ្វើការនៅក្នុងឧស្សាហកម្មដែលត្រូវការជំនាញខ្ពស់ នៅពេលដែលពួកគេត្រឡប់មកប្រទេសវិញ ។

**ឯកឧត្តម ប្រាក់ សុខុន** បានអះអាងជាថ្មីម្តងទៀត នូវការគាំទ្រយ៉ាងមុតមាំរបស់ ឯកឧត្តម ចំពោះ «វេទិកាធុរកិច្ចមេគង្គ-សាធារណរដ្ឋកូរ៉េ» ដែលជាវេទិកាដ៏មានសារសំខាន់ និងផ្តល់ផលប្រយោជន៍ សម្រាប់ភ្ជាប់ទំនាក់ទំនងពាណិជ្ជករ ជាពិសេស សហគ្រាសធុនតូច និងមធ្យម នៅក្នុងខ្សែសង្វាក់ផលិតកម្មតំបន់ និងពិភពលោក។ **ឯកឧត្តម** ក៏មានសេចក្តីរីករាយផងដែរ ដែលប្រទេសកម្ពុជាអាចទាញយក «មូលនិធិសហប្រតិបត្តិការមេគង្គ-សាធារណរដ្ឋកូរ៉េ» ដើម្បីអនុវត្តនៅក្នុងឆ្នាំនេះ នូវគម្រោងកសាងសមត្ថភាពលើការគ្រប់គ្រងមូលដ្ឋានទិន្នន័យភស្តុភារ ដែលមានគោលបំណងពង្រឹងការតភ្ជាប់ពាណិជ្ជកម្មរបស់ប្រទេសកម្ពុជាជាមួយប្រទេសឡាវនិងវៀតណាម។

កិច្ចប្រជុំកំពូលបានអនុម័តថ្លែងការណ៍ស្តីពីទន្លេមេគង្គនិងទន្លេហាន និងបានឯកភាពបន្តកិច្ចសហប្រតិបត្តិការមេគង្គ-សាធារណរដ្ឋកូរ៉េ ដោយផ្អែកលើសសរស្តម្ភចំនួនបី គឺ ប្រជាជន វិបុលភាព និងសន្តិភាព ដែលជាសសរស្តម្ភដ៏សំខាន់របស់គោលនយោបាយទិសខាងត្បូងថ្មីផងដែរ ព្រមទាំងបានអនុម័តវិស័យអាទិភាពថ្មីចំនួន ៧ ៖ (i) វប្បធម៌និងទេសចរណ៍ (ii) ការអភិវឌ្ឍធនធានមនុស្ស (iii) កសិកម្មនិងអភិវឌ្ឍន៍ជនបទ (iv) ហេដ្ឋារចនាសម្ព័ន្ធ (v) ព័ត៌មានវិទ្យានិងបច្ចេកវិទ្យាទូរគមនាគមន៍ (iv) បរិស្ថាន និង (vii) បញ្ហាប្រឈមសន្តិសុខមិនមែនប្រពៃណី។

កិច្ចប្រជុំកំពូលបានឯកភាពរៀបចំកិច្ចប្រជុំកំពូលមេគង្គ-សាធារណរដ្ឋកូរ៉េ ជារៀងរាល់ឆ្នាំ ស្របពេលជាមួយកិច្ចប្រជុំកំពូលអាស៊ាននិងកិច្ចប្រជុំកំពូលពាក់ព័ន្ធ ដោយមានសាធារណរដ្ឋកូរ៉េ និងប្រទេសមេគង្គមួយធ្វើជាសហប្រធាន។

<u>កិច្ចប្រជុំទ្វេភាគី</u>

ក្រៅពីអញ្ជើញចូលរួមកិច្ចប្រជុំកំពូលខាងលើ នៅថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៩ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ប្រាក់ សុខុន** បានទទួលការចូលជួបសម្តែងការគួរសមដោយ **ឯកឧត្តម អូ កែដុន** អភិបាលក្រុងប៊ូសាន និងបានជួបពិភាក្សាទ្វេភាគីជាមួយលោកជំទាវ **កាង យ៉ុង-វ៉ា** រដ្ឋមន្ត្រីការបរទេសនៃសាធារណរដ្ឋកូរ៉េ។

នៅក្នុងសវនាការ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានថ្លែងអំណរគុណដល់អភិបាលក្រុងប៊ូសាន ដែលបានទទួលស្វាគមន៍យ៉ាងកក់ក្តៅចំពោះវត្តមានរបស់គណៈប្រតិភូកម្ពុជា។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំរបស់រដ្ឋបាលក្រុងប៊ូសាន ក្នុងការរៀបចំព្រឹត្តិការណ៍ជាច្រើន ដើម្បីអបអរសាទរទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការដែលកាន់តែប្រសើរឡើង រវាងសាធារណរដ្ឋកូរ៉េនិងប្រទេសជាសមាជិកអាស៊ាន រួមមាន កម្មវិធីមហោស្រពអាហារអាស៊ាន កម្មវិធីរៀបចំដាក់ឈ្មោះ«វិថីអាស៊ាន» កម្មវិធីមហោស្រពភាពយន្តអាស៊ាន និងការដាក់សម្ពោធអគារមជ្ឈមណ្ឌលសហគមន៍សម្រាប់អ្នកស្នាក់នៅជាជនបរទេស។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** និងអភិបាលក្រុងប៊ូសាន ក៏បានផ្លាស់ប្តូរយោបល់គ្នាលើការលើកកម្ពស់កិច្ចសហប្រតិបត្តិការរវាងរាជធានីភ្នំពេញ និងទីក្រុងប៊ូសាន អំពីការអភិវឌ្ឍទីក្រុងឆ្លាត ការរៀបចំទីក្រុង និងការគ្រប់គ្រងទឹក តាមរយៈទំនាក់ទំនងដែលមានស្រាប់នៃសម្ព័ន្ធមេត្រីភាពទីក្រុងនិងទីក្រុង។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានសំដែងនូវការគាំទ្រនិងស្វាគមន៍យ៉ាងពេញទំហឹងចំពោះកិច្ចសហការរបស់ទីក្រុងប៊ូសាន ក្នុងការអភិវឌ្ឍឧស្សាហកម្មភាពយន្ត ការគ្រប់គ្រងកំពង់ផែ និងការអភិវឌ្ឍផែស្ងួតនៅកម្ពុជា។ ឆ្លៀតក្នុងឱកាសនោះ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ក៏បានស្នើឱ្យអភិបាលក្រុងប៊ូសាន បន្តផ្តល់ការយកចិត្តទុកដាក់បន្ថែមចំពោះសុខមាលភាពរបស់ប្រជាជនកម្ពុជាចំនួនជាង៩ពាន់នាក់ ដែលកំពុងស្នាក់នៅ និងធ្វើការនៅក្នុងក្រុងប៊ូសាន។

ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ប្រាក់ សុខុន** បានជួបជាមួយលោកជំទាវ **កាង យ៉ុង-វ៉ា** រដ្ឋមន្ត្រីការបរទេសនៃសាធារណរដ្ឋកូរ៉េ ដើម្បីពិភាក្សាអំពីកិច្ចសហប្រតិបត្តិការទ្វេភាគីរវាងកម្ពុជានិងសាធារណរដ្ឋកូរ៉េ។ ជាកិច្ចចាប់ផ្តើម លោកជំទាវ **កាង យ៉ុង-វ៉ា** សម្តែងការសោកស្តាយដែលមិនអាចស្វាគមន៍**សម្តេចតេជោនាយករដ្ឋមន្ត្រី** អញ្ជើញចូលរួមកិច្ចប្រជុំកំពូលទាំងពីរនៅទីក្រុងប៊ូសាន ដោយសារតែមាតាក្មេករបស់**សម្តេចតេជោ**មានជំងឺធ្ងន់ធ្ងរ។ លោកជំទាវបានពាំនាំនូវការជូនពរពី ឯកឧត្តមប្រធានាធិបតី **មូន ចែអ៊ីន** សូមឲ្យមាតាក្មេករបស់**សម្តេចតេជោ** ឆាប់ជាសះស្បើយ។

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ថ្លែងអំណរគុណចំពោះបដិសណ្ឋារកិច្ចដ៏កក់ក្តៅ និងការជូនពររបស់ឯកឧត្តមប្រធានាធិបតី **មូន ចែអ៊ីន**។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី**ក៏បានរំលឹកផងដែរអំពីទស្សនកិច្ចផ្លូវរដ្ឋប្រកបដោយផ្លែផ្កា របស់ឯកឧត្តមប្រធានាធិបតី **មូន ចែអ៊ីន** នៅកម្ពុជា កាលពីខែមីនាកន្លងទៅនេះ ដែលបានរួមចំណែកធ្វើឲ្យទំនាក់ទំនងទ្វេភាគីកម្ពុជា-សាធារណរដ្ឋកូរ៉េ កាន់តែស៊ីជម្រៅថែមទៀត។

រដ្ឋមន្ត្រីការបរទេសទាំងពីរបានពិភាក្សា និងផ្លាស់ប្តូរយោបល់គ្នា លើកិច្ចសហប្រតិបត្តិការនៅក្នុងវិស័យជាច្រើនរួមមាន វិនិយោគ ពាណិជ្ជកម្ម ការតភ្ជាប់ ហិរញ្ញវត្ថុ កសិកម្ម ថាមពល ការគ្រប់គ្រងកាកសំណល់ និងការប្រាស្រ័យទាក់ទងរវាងប្រជាជននិងប្រជាជន ហើយបានសម្តែងក្តីរីករាយដែលភាគីទាំងពីរបានឯកភាពគ្នា

ចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តីពីការលុបបំបាត់ការយកពន្ធត្រួតគ្នា ពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល និង ការបង្ការការគេចពន្ធ និង សន្ធិសញ្ញាស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ ដែលមានសារៈសំខាន់សម្រាប់សម្រួលទំនាក់ទំនងរវាងប្រជាជន និងរវាងធុរកិច្ចនៃប្រទេសទាំងពីរ។

ពាក់ព័ន្ធនឹងវិស័យកសិកម្ម រដ្ឋមន្ត្រីការបរទេសទាំងពីរស្វាគមន៍ការចុះហត្ថលេខាដោយរដ្ឋមន្ត្រីកសិកម្មនៃប្រទេសទាំងពីរ លើអនុស្សរណៈនៃការយោគយល់គ្នាស្តីពីការបន្តកិច្ចសហប្រតិបត្តិការលើវិស័យនេះ និងបានឯកភាពគ្នាជម្រុញកិច្ចសហប្រតិបត្តិការក្នុងវិស័យព្រៃឈើ កសិឧស្សាហកម្ម និងការកែច្នៃផលិតផលកសិកម្ម។ រដ្ឋមន្ត្រីការបរទេសទាំងពីរ ក៏បានស្វាគមន៍ដោយរីករាយផងដែរចំពោះការប្រកាសរៀបចំសិក្សារួមគ្នាស្តីពីលទ្ធភាពធ្វើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-សាធារណរដ្ឋកូរ៉េ ដែលអាចនឹងជួយពង្រីកឲ្យកាន់តែធំថែមទៀតនូវពាណិជ្ជកម្មរវាងប្រទេសទាំងពីរ ដែលសព្វថ្ងៃបានកើនដល់ប្រមាណជិត១ពាន់លានដុល្លាអាមេរិករួចហើយ។

ឆ្លៀតក្នុងឱកាសនោះ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី**បានថ្លែងអំណរគុណដល់សាធារណរដ្ឋកូរ៉េ ដែលបាន និងបន្តរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គមកម្ពុជា ដោយថ្មីៗនេះបានសម្រេចបង្កើនកម្ចីសម្បទានសម្រាប់កម្ពុជាដល់ ៧០០លានដុល្លារអាមេរិក ក្នុងរយៈពេលឆ្នាំ២០១៩-២០២៣ និងផ្តល់ជំនួយឥតសំណង ១០លានដុល្លារអាមេរិក គាំទ្រប្រតិបត្តិការដោះមីននៅខេត្តបាត់ដំបង ប៉ៃលិន និងបន្ទាយមានជ័យ។ ចំពោះវិស័យការងារវិញ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានថ្លែងអំណរគុណដល់សាធារណរដ្ឋកូរ៉េ ដែលបានបន្តបង្កើនកូតាទទួលពលករខ្មែរទៅធ្វើការនៅកូរ៉េ និងបានយកចិត្តទុកដាក់ដល់សុខមាលភាពប្រជាជនខ្មែរដែលកំពុងស្នាក់នៅធ្វើការនៅសាធារណរដ្ឋកូរ៉េ។

រដ្ឋមន្ត្រីការបរទេសទាំងពីរក៏បានពិភាក្សាពីកិច្ចសហប្រតិបត្តិការក្នុងក្របខ័ណ្ឌតំបន់ និងអន្តរជាតិផងដែរ។ លោកជំទាវ **កាង យ៉ុង-វ៉ា** បានស្នើកម្ពុជាគាំទ្រដល់សាធារណរដ្ឋកូរ៉េ ដែលនឹងធ្វើជាម្ចាស់ផ្ទះរៀបចំ **កិច្ចប្រជុំកំពូលលើកទី២ ស្តីពីភាពជាដៃគូដើម្បីកំណើនបៃតង និង គោលដៅពិភពលោក២០៣០** (2nd P4G Summit: Partnership for Green Growth and the Global Goals 2030) ដែលគ្រោងនឹងរៀបចំនៅខែមិថុនា ឆ្នាំ២០២០ នៅទីក្រុងសេអ៊ូល។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** សន្យាផ្តល់កិច្ចសហប្រតិបត្តិពេញទំហឹង ហើយបានបញ្ជាក់ថាកម្ពុជានឹងបញ្ជូនគណប្រតិភូជាន់ខ្ពស់ចូលរួមក្នុងកិច្ចប្រជុំកំពូលនេះ។

ក្រោយពីបញ្ចប់ជំនួបទ្វេភាគី ដែលបានប្រព្រឹត្តទៅក្នុងបរិយាកាសដ៏ស្និទ្ធស្នាល រដ្ឋមន្ត្រីការបរទេសទាំងពីរបានចុះហត្ថលេខាលើឯកសារដ៏សំខាន់ចំនួនពីរ គឺ ១) កិច្ចព្រមព្រៀងស្តីពីការលុបបំបាត់ការយកពន្ធត្រួតគ្នា ពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល និងការបង្ការការគេចពន្ធ និង ២) សន្ធិសញ្ញាស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ។

ថ្ងៃព្រហស្បតិ៍ ២កើត ខែមិគសិរ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៩